# ពុទ្ធិកសមាគមខ្មែរ,ឥង្ក.

The Cambodian Buddhist Society, Inc.

13800 New Hampshire Avenue, Silver Spring, MD 20904

Tel: (301) 622-6544


# បុណ្យចូលឧស្សា

••••••••••

ពិធីចូលព្រះវស្សា ជាបុណ្យមួយសំខាន់ក្នុងព្រះពុទ្ធសាសនា ព្រោះជាឱកាសដែលភិក្ខុសង្ឃក្នុងព្រះពុទ្ធសាសនាអធិដ្ឋានចូលព្រះវស្សា នៅអាស្រ័យតែមួយកន្លែងក្នុងទីអាវាសណាមួយ មិនត្រាច់ចររហេតរហូត ក្នុងរយៈពេលរដូវភ្លៀង ៣ ខែ ចាប់ពីថ្ងៃ ១ រោច ខែ អាសាធ ដល់ថ្ងៃ ១៥ កើត ខែ អស្សុជ រៀងរាល់ឆ្នាំ វៀរលែងតែឆ្នាំដែលលើកខែតែប៉ុណ្ណោះ ។

ពិធីចូលព្រះវស្សាជាពុទ្ធប្បញ្ញត្តិ គឺជាច្បាប់វិន័យដែលព្រះពុទ្ធទ្រង់បានបញ្ញត្តចំពោះសង្ឃសាវ័ករបស់ព្រះអង្គ ដើម្បីសេចក្តីរៀបរយក្នុងសាសនារបស់ព្រះអង្គផងដើម្បីរក្សានូវសទ្ធាជ្រះថ្លារបស់ទាយកទាយិកាផង ។

## កាលបរិច្ឆេទ

នៅទីវត្តពុទ្ធិការាម លេខ ១៣៨០០ មហាវិថីញូវហាំស៊ារ ស៊ិលវើស្ព្រីង រដ្ឋម៉េរីឡែន ២០៩០៤

- ថ្ងៃព្រហស្បតិ៍ ១៥ កើត ខែទុតិយាសាធ ព.ស. ២៥៥៦ ត្រូវនឹងថ្ងៃទី ២ ខែសីហា គ.ស. ២០១២

  ម៉ោង ៧ : ០០ ល្ងាច : ជួបជុំពុទ្ធបរិស័ទ ហែទៀនព្រះវស្សាប្រទក្សិណាព្រះវិហារ ៣ ជុំ
  : នមស្ការព្រះរតនត្រ័យ សមាទានសីល វេរទៀនព្រះវស្សា
  : ចម្រើនព្រះបរិត្ត ធម្មទេសនា

- ថ្ងៃសុក្រ ១ រោច ខែទុតិយាសាធ ព.ស. ២៥៥៦ ត្រូវនឹងថ្ងៃទី ៣ ខែសីហា គ.ស. ២០១២

  ម៉ោង ៧ : ០០ ព្រឹក : ប្រគេនយាគូចំពោះព្រះសង្ឃ
  ម៉ោង ៩ : ៣០ នាទីព្រឹក : នមស្ការព្រះរតនត្រ័យ សមាទានសីល សូធ្យព្រះបរិត្ត
  : រាប់បាត្រ ដារ បង្សុកូល វេរភត្ត
  : វេរសំពត់សាដកប្រគេនព្រះសង្ឃ
  ម៉ោង ១១ : ០០ ព្រឹក : ប្រគេនចង្ហាន់ត្រង់ចំពោះព្រះសង្ឃ
  : ភត្តានុមោទនា ពហូទេវាឆ្លងជាកិច្ចបញ្ចប់បុណ្យ

សូមអញ្ជើញ លោកតា លោកយាយ លោកមា លោកមីង លោក អ្នកនាង ទាំងឡាយ ទៅចូលរួមធ្វើបុណ្យចូលព្រះវស្សា តាមកម្មវិធីនិងកាលបរិច្ឆេទខាងលើនេះ ដើម្បីអនុមោទនា យកផលានិសង្ស តាមកម្លាំងសទ្ធាជ្រះថ្លារៀង ៗ ខ្លួន ៕

ក្រុមអភិបាលនៃពុទ្ធិកសមាគមខ្មែរ,ឥង្ក.

តំបន់វ៉ាស៊ិនតុន, ឌី.ស៊ី.

ពុទ្ធិកសមាគមខ្មែរ,ឥន្ក.
The Cambodian Buddhist Society, Inc.
13800 New Hampshire Avenue, Silver Spring, MD 20904
Tel: (301) 622-6544

# PROGRAM
# of
# VASSA CEREMONY

(The Rainy Season Retreat)

@@@@@

The three-month rainy season ( THE VASSA ) is one of the important events in Buddhism . It has been strictly observed by Buddhist Monks since the life time of the Buddha, and it still prevails.

In order to preserve this tradition, the Cambodian Buddhist Society, Inc. will celebrate the VASSA according to the following schedule:

<u>SCHEDULE</u>

At Vatt Buddhikarama, 13800 New Hampshire Avenue, Silver Spring , MD 20904

- <u>Thursday, August 2, 2012</u>

| | |
|---|---|
| 7:00 pm | : The VASSA candle procesion; Paying respect to |
| | : the Triple Gem; Taking the five Precepts; Offering |
| | : of the VASSA candle; Chanting the Paritta; Lecture |
| | : on Dhamma |

- <u>Friday, August 3, 2012</u>

| | |
|---|---|
| 7:00 am | : Breakfast for Buddhist Monks |
| 9:30 am | : Paying Respect to the Triple Gem; Taking the Five |
| | : Precepts; Alms Giving; Food Offering; |
| | : Robe Offering |
| 11:00 am | : Lunch for Buddhist Monks |

You, your family and friends are cordially invited to participate in the VASSA ceremony with us.

The Board of Director
The Cambodian Buddhist Society, Inc.